# ការដឹងគុណចំពោះមាតាបិតា

THE GRATITUDE TOWARDS PARENTS

## អ្វីគឺការដឹងគុណ?

What is gratitude?

ការដឹងគុណគឺជាកាតព្វកិច្ចដែលមនុស្សក្នុងសកលលោកយើងនេះ គួរតែសន្សំទុកនិងបណ្ដុះឱ្យមាននៅក្នុងសន្ដានរបស់យើងម្នាក់ៗ។ ការដឹងគុណជាគន្លឹះមួយដែលធ្វើឱ្យមានតុល្យភាពរវាងអ្នកធ្វើគុណនិងអ្នកទទួលគុណពីគេ។ គុណនេះមានន័យថាធម្មជាតិទ្រទ្រង់ ឬសារត្ថ:តភ្ជាប់មនុស្សអោយប្រាស្រ័យទាក់ទងគ្នាបានល្អ និងសុខសន្តិភាព។ អ្នកធ្វើគុណនិងអ្នកទទួលគុណ មានទំនាក់ទំនងជាប់គ្នាជានិច្ច មិនអាចកាត់ផ្ដាច់ពីគ្នាបានឡើយ។ តែសំរាប់អ្នកទទួលគុណ គួរតែសំដែងសេចក្ដីដឹងគុណ (កតញ្ញូតាធម៌) ដោយ ការបដិបត្តិអោយត្រឹមត្រូវ និងប្រព្រឹត្តតែអំពើល្អជាដើម ។

## គុណមាតាបិតា ជាគុណដ៏ធំមហិមា

The virtue of parents is most gigantic

អ្នកដឹងគុណដល់ជនដទៃ ហើយធ្វើគុណនោះតបវិញ ឈ្មោះថាមនុស្សល្អ ដូចដែលពុទ្ធភាសិតពោលថា “ **និមិត្តំ សាធុ រូបំ កតញ្ញូកតវេទិតា**” ។ ការធ្វើគុណមានច្រើនប្រភេទផ្សេងៗពីគ្នា ប៉ុន្តែគុណដែលធ្ងន់ជាងគេ គឺគុណរបស់មាតាបិតា។ ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គទ្រង់បំពេញពុទ្ធកិច្ចមួយគ្រប់ជាតិរបស់ព្រះអង្គ គឺចិញ្ចឹមនិងទំនុកបំរុងមាតាបិតា។ រហូតដល់ចុងបញ្ចប់ក្នុងកំណើតជាព្រះពុទ្ធ ព្រះអង្គទ្រង់ចំណាយពេលច្រើនជាងគេក្នុងការទេសនាប្រៀនប្រដៅមាតាបិតា។ព្រះសមណគោត្តមនៃយើងទ្រង់សំដែងព្រះអភិធម្មទាំង៧គម្ពីរ ប្រោសព្រះមាតាក្នុងឋានតាវតឹង្ស[១] អស់រយៈពេលមួយព្រះវស្សាពេញ។ តាមពិតពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូត្របាន៧ថ្ងៃ ព្រះមាតាទ្រង់ចូលទីវង្គត់ហើយទៅបដិសន្ធិក្នុងឋានតុសិត។ តែហេតុអ្វីបានជា ព្រះពុទ្ធអង្គទៅសំដែងធម៌ក្នុងឋានទាបជាងគឺតាវតឹង្សព្រោះព្រះអង្គចង់អោយព្រះមាតាព្យាយាមមកស្ដាប់ធម៌ដោយព្រះអង្គផ្ទាល់។ អត្ថកថាចារ្យបានអធិប្បាយថាការស្ដាប់ធម៌ព្រះអភិធម្មបានអានិសង្សច្រើនណាស់ ដូច្នេះមួយជំហានរបស់ព្រះមាតាព្រះពុទ្ធអង្គ បានអានិសង្សច្រើនរាប់អសង្ខ័យ ។

---

១. ឋានសួគ៌ា៦ជាន់ : ចតុមហារាជការ, តាវតឹង្សា, យាមា, តុសិត, និម្មារតី និង បរិនិមិត្តសវតី

គុណដ៏ធំធេងរបស់មាតាបិតានេះ ស្របនឹងសុភាសិតបុរាណខ្មែរពោលថា *"ម៉ែឪមានគុណ គុណមានទំងន់ ធ្ងន់ដូចប្រថពី គ្មានអ្វីនឹងស្មើ គុណលោកទាំងពីរ មាសប៉ុនគីរី ថ្លៃពុំស្មើហោង"* ។

គុណរបស់មាតាបិតាមានច្រើនណាស់ ជាអនន្តគុណ អប្បមាណគុណ អនេកគុណ និង អសមគុណ ។

១. **អនន្តគុណ** (endless virtue) គឺគុណជាអនន្ត ដែលយើងមិនអាចគណនាបានដោយតួលេខបូក ដក គុណ ចែក ជាគុណដែលគ្មានព្រំដែន គ្មានទីបញ្ចប់ ។

២. **អប្បមាណគុណ**(unestimated virtue) គឺគុណដែលមិនអាចប្រមាណបាន មិនអាចស្រមើស្រមៃបានថាប៉ុណ្ណេះ ប៉ុណ្ណោះបានឡើយ ។ តាមប្រពៃណីខ្មែរយើងខ្លះជឿថា បួសសាមណេរដើម្បីសងគុណម្តាយ ហើយបួសភិក្ខុដើម្បីសងគុណឪពុក ។ ការជឿដូច្នេះគឺមិនត្រឹមត្រូវទេ គុណរបស់ម្តាយឪពុក គឺមិនអាចប្រមើលមើលឬកាក់ស្មានបានឡើយ ។

៣. **អនេកគុណ**(unsurpassed virtue) គឺគុណច្រើនអនេកកប្បការ ជាគុណធំមហិមា ខ្ពស់មហិមា ជ្រៅមហិមា ។

៤. **អសមគុណ**(unequal virtue) គឺជាគុណដែលគ្មានអ្វីអាចយកមកប្រៀបធៀបឱ្យស្មើបាន ។

## មាតាបិតាជាអរិយបុគ្គលប្រាំយ៉ាងរបស់បុត្រាបុត្រី

Parents are the five noble persons of every child

ព្រះសម្មាសម្ពុទ្ធទ្រង់ប្រៀបធៀបមាតាបិតា ទៅនឹងបុគ្គល៥យ៉ាងគឺលោកជាព្រះព្រហ្ម លោកជាបុព្វទេវា លោកជាបុព្វាចារ្យ និងលោកជាព្រះអាហុនេយ្យៈ ។

១. **ព្រះព្រហ្ម**(Brahma or the god of creator)

ជាព្រះដែលខ្ពស់ជាងគេបង្អស់ក្នុងសាសនាព្រាហ្មណ៍ ។ ជំនឿក្នុងគម្ពីរព្រះវេទ ព្រះព្រហ្មទាំងជាអ្នកបង្កើតផង ហើយទាំងជាអ្នកបំផ្លាញផង ។ តែក្នុងព្រះពុទ្ធសាសនា ព្រះព្រហ្មគឺព្រហ្មវិហារធម៌ទាំងបួន មានដូចជា :

- មេត្តា(Loving-kindness)

សេចក្តីស្រលាញ់ ថ្នាក់ថ្នមបុត្រាបុត្រីដោយមិនមានការខ្លាចនឿយហត់ មានចិត្តធុញថប់ចំពោះកូន ។ ម្តាយពរផ្ទៃពោះតាំងពីកូនចាប់បដិសន្ធិ ធំធាត់ចំរើនវ័យក្នុងឧទរ មានការតមអាហារ ថ្នាក់ថ្នមគ្រប់ឥរិយាបថដេក ដើរ ឈរ អង្គុយ ។ មានចិត្តរំភើបញាប់ញ័រពេលឃើញបុត្ររបស់ខ្លួនកំរើកឱ្យសញ្ញាម្តងៗ ។ ជួនកាលម្តាយឪពុកច្រៀងបំពេរ ស្រែកហៅ ដាក់ឈ្មោះ

ប្រលោមអង្អែលលែង គ្រប់ទិវារាត្រី ។ ថ្ងៃដែលប្រសូត្រជាឱកាសស្លាប់រស់របស់ម្តាយដែលខ្មែរយើងហៅថាឆ្លងទន្លេ ជាការផ្សងជីវិតទៅនឹងគ្រោះថ្នាក់ដែលគ្មាននរណាអាចដឹងជាមុនបាន ។ កើតមកហើយ ចិញ្ចឹមបីបាច់ ថ្នាក់ថ្នម បំបោសអង្អែល ជូតទឹកក្តៅទឹកប្រជាក់ ថែទាំមិនឱ្យមានសត្វសាហាវ ស្រមោច សង្ការ មូស រុយ មករោម ចឹក ខាំ សូម្បីតែស្នាមកន្ទួលបន្តិចក៏មិនចង់ឱ្យមានផង ។ ពេលជុះនោមម្តងៗ ឪពុកម្តាយស្ទាបអង្អែលទឹកមូត្រលាមកស្មើរតែគ្រប់ពេលឥតមានអារម្មណ៍ខ្ពើមរអើមបន្តិចសោះឡើយ ។ ជួនកាលនោមជុះដាក់លើភ្លៅឆ្វេង លើកដាក់លើភ្លៅស្តាំ ហើយជូតភ្លៅឆ្វេងមិនទាន់ទាំងស្ងួតផង ស្រាប់តែជុះអាចម៍ដាក់លើភ្លៅស្តាំទៀត ។ តែឪពុកម្តាយគ្មានមាត់មួយម៉្អឺះសោះ មានតែសើចសប្បាយត្រេកអរជាមួយនឹងកូនទៀត ។ នេះហើយសេចក្តីស្រលាញ់ដ៏ស្មោះស្ម័គ្ររបស់ឪពុកម្តាយចំពោះកូន ។

- ករុណា (Compassion)

គឺសេចក្តីអាណិតអាសូរ ដែលឪពុកម្តាយមិនមែនត្រឹមតែស្រលាញ់កូនទេ ថែមទាំងអាណិតផង ។ អាណិតមានន័យកាន់តែជ្រៅជាងស្រលាញ់ទៅទៀត ដូចពាក្យខ្មែរយើងពោលថា “ *ស្រលាញ់មិនប្រសព្វស្មើអាណិតមួយ* ” ។ ស្រលាញ់ច្រើនតែសំដែងតាមរយៈកាយវិការខាងក្រៅ ប៉ុន្តែអាណិតច្រើនជ្រាលជ្រៅដល់ក្រអៅបេះដូងតែម្តង ។ ឪពុកម្តាយអាណិតកូនតាំងពីកូននៅក្នុងផ្ទៃ រហូតធំដឹងក្តីពេញរូបពេញរាង មានគូរស្រករ បែកទៅរស់នៅឆ្ងាយយ៉ាងណាក៏ដោយ ក៏ទឹកចិត្តឪពុកម្តាយរមែងនឹកដល់កូនជានិច្ច ។ ការនឹកនេះផុសចេញពីការអាណិត (ករុណា) ដែលផុះចេញពីក្រអៅបេះដូងពិតៗតែម្តង ។ ដូចពាក្យបុរាណខ្មែរយើង រមែងពោលថា “ *ម្តាយនឹកកូនដូចច្រវ៉ាប្រវែញ កូននឹងម្តាយវិញដូចព្រះបែរខ្នង* ” ។ ដូចយើងដឹងហើយថា បើយើងបូជាព្រះនៅចំពីមុខ យើងនឹងឃើញព្រះភ័ក្រព្រះ ហើយព្រះក៏សំលឹងមើលមកយើងវិញដោយមេត្តាគុណ វិសុទ្ធិគុណ និងបញ្ញាគុណដ៏ជ្រាលជ្រៅបំផុត ។ តែបើយើងបូជាព្រះនៅពីក្រោយខ្នងវិញ យើងនឹងគ្មានបានអ្វីទាំងអស់ បើបានក៏បានតិចតួចស្តួចស្តើងបំផុត ។ ដូច្នេះហើយបានជាលោកប្រៀបធៀបទៅនឹងកូនភាគច្រើន រមែងនឹកដល់ឪពុកម្តាយគ្រាន់តែជាមនោភាពសាមញ្ញធម្មតាប៉ុណ្ណោះ មិនមែននឹកដល់ឪពុកម្តាយដោយចេញពីក្រអៅបេះដូងពិតៗ ដូចដែលម្តាយឪពុកនឹកកូនឡើយ ។

- មុទិតា (Sympathetic-joy)

គឺសេចក្តីមានអារម្មណ៍រួមជាមួយ បើមានទុក្ខនឹងជួយរំលែកទុក្ខបើសុខនឹងត្រេកអរសាទរជាមួយ ។ ឪពុកម្តាយរមែងក្តុលក្តួលអួលណែនឱរ៉ា បើដឹងឬឃើញថាបុត្រជួបប្រសព្វនូវសេចក្តីទុក្ខ ។ មិនតែប៉ុណ្ណោះនឹងហ៊ានលះបង់គ្រប់បែបយ៉ាង សូម្បីតែជីវិតក៏ហ៊ានប្តូរដែរ ដើម្បីធ្វើយ៉ាងណា អាចរំដោះ

បុត្រអោយចេញផុតពីសេចក្តីទុក្ខបាន។ តែបើឃើញឬដឹងថាបុត្របានសេចក្តីសុខ ឬបានជោគជ័យនូវអ្វីមួយ ឪពុកម្តាយនឹងមានបីតិសោមនស្សរីករាយ ត្រេកអរ រំភើបក្នុងចិត្ត ហាក់ដូចជាបានសំរេចធម៌លោកុត្តរៈ មានសោតាបដិមគ្គជាដើម។ ឪពុកម្តាយនឹងគ្មានទាល់តែសោះ នូវអារម្មណ៍ច្រណែននិន្ទាចំពោះកូន ដែលទង្វើរនេះផ្ទុយស្រលះពីជនដ៏ទៃ ទោះបីជាមិត្តភក្តិក្តីឬបងប្អូនខ្លួនឯងក្តី រមែងមានចិត្តច្រណែននូវជោគជ័យរបស់យើងណាមួយ ។

- ឧបេក្ខា(Equanimity)

គឺសេចក្តីមិនលំអៀងដោយអគតិធម៌បួនយ៉ាងមានមិនលំអៀងព្រោះតែស្រលាញ់ មិនលំអៀងព្រោះតែស្អប់ មិនលំអៀងព្រោះតែភិតភ័យនិងមិនលំអៀងព្រោះតែវង្វេង។ ឧបេក្ខាធម៌ ជាធម៌ដែលពិបាកបដិបត្តិជាងគេ។ អ្នកដែលបដិបត្តិធម៌នេះជារៀងរាល់ថ្ងៃគឺតុលាការ ប៉ុន្តែតុលាការមិនអាចបដិបត្តិធម៌នេះឱ្យត្រង់ ត្រឹមត្រូវបានឡើយ។ មានតែឪពុកម្តាយចំពោះកូនចៅតែប៉ុណ្ណោះ ដែលមានធម៌នេះ។ ក្រៅពីឪពុកម្តាយ មានតែព្រះសម្មាសម្ពុទ្ធនិងព្រះអរហន្តតែប៉ុណ្ណោះ ដែលមានឧបេក្ខាធម៌ពិតប្រាកដនៅក្នុងក្រអៅបេះដូង ។ តែឧបេក្ខារវាងព្រះអរហន្តនិងមាតាបិតាខុសគ្នាឆ្ងាយណាស់ ព្រោះមាតាបិតាមានចំពោះតែកូនចៅរបស់ខ្លួនឯង ចំណែកកូនចៅអ្នកដទៃមិនមានឡើយ។

២. **ព្រះបុព្វទេវា**(former god)

គឺជាទេវតាខាងដើម។ដូចដែលយើងដឹងហើយទេវតាជាតំណាងឱ្យឧត្តមគតិ ខាងគុណធម៌ភាពស្រស់ថ្លាគ្មានមន្ទិលសៅហ្មង ឬតំណាងឱ្យការស្រលាញ់ ការអាណិត ការអាសូរដ៏ជ្រាលជ្រៅដែលគ្មានព្រំដែន ។ មនុស្សយើងម្នាក់ៗ បើនិយាយពីទេវតា រមែងស្រលាញ់ស្មោះស្ម័គ្រចំពោះទេវតាទាំងនោះ។ ដូចគ្នាដែរតាំងពីបុត្រចូលមកបដិសន្ធិ ធំធាត់រហូតដល់ធំពេញវ័យយ៉ាងណាក៏ដោយ ឪពុកម្តាយជាបុគ្គលទីមួយដែលស្រលាញ់ស្មោះស្ម័គ្រចំពោះកូនមុនគេ(បុព្វេ)។លោកទាំងពីរជាទេវតាដែលមានសេចក្តីស្រលាញ់បរិសុទ្ធិ មិនមែនស្រលាញ់ព្រោះតែសំលឹងមើលផលប្រយោជន៍ពីបុត្រសោះឡើយ។

៣. **ព្រះបុព្វាចារ្យ**(former teacher)

គឺជាគ្រូខាងដើម ដែលបង្រៀនប្រៀនប្រដៅយើង ឱ្យចេះក្រឡាប់ ចេះវារ ចេះអង្គុយ ចេះនិយាយ ចេះឈរ និងចេះដើរ។ នៅពេលយើងធំល្មមដឹងវ័យខ្លះ លោកទាំងពីរ រមែងអប់រំទូន្មានបុត្រឱ្យតំកល់ខ្លួននៅក្នុងអំពើល្អ នៅក្នុងគុណធម៌ ព្រមទាំងបញ្ជូនកូនទៅសាលារៀន សិក្សារៀនសូត្រអក្សរ ការសម្របខ្លួនទៅតាមបរិដ្ឋានសង្គម និងសិល្បៈវិជ្ជាផ្សេងៗ ដើម្បីបានជាឯកទេសវិជ្ជាជីវៈប្រចាំជីវិតរបស់ខ្លួន ។ គ្រូរបស់យើងទាំងឡាយមានពីរគឺ *បុព្វាចារ្យ*ជាគ្រូខាងដើម

មានតែឪពុកម្ដាយរបស់យើងទេ ហើយគ្រូទីពីរគឺ*មច្ឆាចារ្យ* ជាគ្រូខាងក្រោយ មានគ្រូបង្ហាត់អក្សរសាស្ត្រ អក្សរសិល្ប៍ គណិតវិទ្យា ភូមិវិទ្យា រូបវិទ្យា ឬសីលធម៌ ជាដើម។

៤. **ព្រះអាហុនេយ្យ**(worthy of offerings)

គឺជាព្រះអរហន្ត ជាអរិយសាវ័កនិងសង្ឃសាវ័កទាំងឡាយដែលគួរទទួលនូវចតុបច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចំងាយបង្អោនចូលមកបូជា។ ដូច្នេះកូនចៅបុត្រាបុត្រីត្រូវសំគាល់ឪពុកម្ដាយថា ជាព្រះអរហន្តនៅក្នុងផ្ទះរបស់យើង ដែលយើងទាំងឡាយគួរក្រាបថ្វាយបង្គំបូជាដោយគ្រឿងឧបភោគបរិភោគ មានសំលៀកបំពាក់ បាយទឹកនំចំណី បន្ទប់ដេកបន្ទប់អង្គុយ និងថ្នាំរក្សាព្យាបាល។ បុត្រាបុត្រីភាគច្រើននិយមទៅក្រាបថ្វាយបង្គំព្រះសង្ឃនៅឯវត្ត តែមិនដែលក្រាបថ្វាយបង្គំឪពុកម្ដាយដែលជាព្រះអរហន្តនៅក្នុងផ្ទះសោះ ឬនិយមយកចំណីអាហារប្រណីតៗទៅតែវត្ត ប៉ុន្តែទុកឱ្យឪពុកម្ដាយកូរពោះនៅឯផ្ទះ។ ការធ្វើបុណ្យដូច្នេះគឺបុណ្យរំលងព្រះពិតប្រាកដហើយ ។

## ការតបស្នងសងគុណ ជាករណីយកិច្ចរបស់បុត្រាបុត្រីទាំងឡាយ

Paying gratitude is every child’s duty

ដូចដែលអធិប្បាយមកហើយ គុណរបស់មាតាបិតាមានអនេកកប្បការ ដែលយើងមិនអាចសងដោយវិស័យជាបុថុជ្ជនបានឡើយ។ តែយើងត្រូវតែព្យាយាមធ្វើកុំឱ្យដាច់ ចុះបើយើងតែងតែ ភ្លេច ឬព្រងើយកន្តើយវិញ សួរថាតើយើងអាចតបស្នងសងគុណបានប៉ុណ្ណា?។ ព្រះពុទ្ធជាម្ចាស់សរុបគុណទាំងឡាយមកត្រឹមបីទៀតគឺអដ្ឋិគុណ វិសេសគុណ គុណូបការគុណ ។

១. **អដ្ឋិគុណ**(relic virtue) គឺគុណឆ្អឹងធាតុទាំងបួន[២] ដែលលោកបានបង្កើតយើងមក

២. **វិសេសគុណ**(extraordinary virtue) គឺគុណវិសេសជាងគុណអ្វីទាំងអស់នៅក្នុងលោក

៣. **គុណូបការគុណ**(meritorious virtue) គឺគុណបីបាច់ថែរក្សា ថ្នាក់ថ្នមបញ្ចុកនំចំណីឱ្យយើងធំធាត់ដឹងក្ដី ។

ម្យ៉ាងវិញទៀត មាតាបិតានិងបុត្ររមែងមានទំនាក់ទំនងរវាងគ្នានឹងគ្នាជានិច្ច ដោយមាតាបិតាបានបំពេញករណីកិច្ច៥យ៉ាងចំពោះបុត្រ គឺ

១. ហាមប្រាមបុត្រាបុត្រីមិនឱ្យធ្វើនូវអំពើបាបទាំងពួង

២. ប្រៀនប្រដៅណែនាំឱ្យតំកល់ខ្លួនតែក្នុងអំពើល្អ

៣. ផ្ដល់ឱកាសឱ្យបានសិក្សាសិល្បៈវិទ្យាផ្សេងៗ

---

២. ធាតុទឹក ធាតុភ្លើង ធាតុដី ធាតុខ្យល់

៤. ទទួលភារៈក្នុងការរកគូរស្រករឱ្យ

៥. ប្រគល់កេរ្តិ៍មរតកឱ្យកូនបានយកទៅធ្វើជាទុនរកស៊ីក្នុងឱកាសដែលសមគួរ

ចំណែកបុត្រាបុត្រីវិញត្រូវបំពេញករណីកិច្ចរបស់ខ្លួនចំពោះមាតាបិតា ៥ យ៉ាងដូចគ្នាគឺ

១. សំដែងសេចក្តីគោរពនិងកតញ្ញូកតវេទិតាធម៌ដល់មាតាបិតា

២. អាសារចូលទៅសួរសុខទុក្ខមាតាបិតា ទទួលយកដំបូន្មានល្អៗពីមាតាបិតា និងជួយបន្ទូរបន្ថយការងារធ្ងន់ស្រាលមួយចំនួនរបស់គាត់ ។

៣. ចូលទៅគោរពប្រណិបត្តិ នៅជិតគាត់ជានិច្ច គោរពពាក្យទូន្មានប្រៀនប្រដៅរបស់គាត់ជានិច្ច និងញុាំងបរិកាសឱ្យគាត់ទាំងពីរមានសេចក្តីត្រេកអរ មានសង្ឃឹមនិងសេចក្តីសុខដោយមានបុត្រាបុត្រីចេះយល់ចិត្ត ចេះយកចិត្ត ។

៤. ខំឧស្សាហ៍ព្យាយាមបំពេញកិច្ចការ ខិតខំប្រឹងប្រែងសិក្សារៀនសូត្រក្រេបយកចំណេះវិជ្ជាទាំងឡាយ មិនប្រព្រឹត្តអំពើអាក្រក់ទាំងពួងជាហេតុធ្វើឱ្យគាត់ទាំងទ្វេរពិបាកចិត្តព្រោះតែយើង ។

៥. ពេលគាត់ចាស់ជរាទៅ ណែនាំឬយកគាត់ទៅជួបព្រះសង្ឃឬចាស់ព្រឹទ្ធាចារ្យដែលមានចំណេះដឹងអាចពន្យល់ធម៌អារ្យដល់គាត់។ ពេលលោកធ្វើមរណកាលទៅយើងត្រូវធ្វើបុណ្យឧទ្ទិសដល់គាត់ឱ្យបានញឹកញាប់ទៅតាមលទ្ធភាពដែលយើងមាន ។

ករណីកិច្ចទាំង៥យ៉ាងនេះ ជាអំពើដែលសំដែងចេញនូវកតញ្ញូកតវេទិតាធម៌ខ្លះរបស់បុត្រាបុត្រីចំពោះមាតាបិតាខ្លួន។ ដើម្បីបដិបត្តិនូវការតបស្នងសងគុណនេះឱ្យមានប្រសិទ្ធិភាពកាន់តែខ្លាំងថែមទៀត គួរបដិបត្តិតាម*បណាម*បីយ៉ាង ឬហៅថា*ត្រៃបណាម* គឺតាមរយៈកាយទ្វារ វចីទ្វារ និងមនោទ្វារ។

១. **កាយបណាម**(bodily practice) ជាការគោរពប្រណិបត្តិដោយផ្លូវកាយមានការធ្វើគារវកិច្ច ការលើកដៃ សំពះ ការថ្វាយបង្គំ ការបំរើទឹកក្តៅទឹកត្រជាក់ ការបីត្រកងថ្នាក់ថ្នមផ្តល់ទីដេក ទីឈរ ទីអង្គុយ ដែលមានភាពសុខស្រួល ប្រាសចាកកង្វល់ទាំងពួង

២. **វចីបណាម**(verbally practice)ជាការប្រើពាក្យសំដីទន់ភ្លន់ មិននិយាយកុហក់ មិននិយាយញុះញង់និយាយ ដើមអ្នកដទៃ មិននិយាយពាក្យអសុរស និងមិននិយាយច្រើនឥតប្រយោជន៍ ចំពោះមាតាបិតា។ និយាយតែពាក្យណាដែលនាំមកនូវសេចក្តីសប្បាយរីករាយចិត្ត ភាសាណាដែលនាំមកនូវសទ្ធានិងការបដិបត្តិធម៌របស់មាតាបិតាឱ្យមានកំលាំងកាន់តែខ្លាំងនិងរស់រវើកខ្លាំងឡើង ។

៣. **មនោបណាម**(mentally practise) ជាការសំដែងចេញនូវផ្នត់គមនិតការត្រិះរិះពិចារណា និងមនោសញ្ចេតនា ដែលល្អត្រឹមត្រូវប្រកបដោយធម៌។ នឹកដល់គុណូប–ការគុណដ៏ធំធេងដែលលោកទាំងពីរ បានបង្កើតយើងមក។

ការតបស្នងគុណដោយការបដិបត្តិបណាមទាំងបីនេះ នៅមិនទាន់គ្រប់គ្រាន់ទេ តែក៏បានខ្លះដែរ បើកុលបុត្រកុលធីតាគ្រប់រូបទាំងអស់ព្យាយាមបដិបត្តិឱ្យបានត្រឹមត្រូវនិងធ្វើជាប្រចាំ។ ក្នុងរឿងជាតក ព្រះសុវណ្ណសាមជាគំរូដ៏ល្អក្នុងការបដិបត្តិចំពោះមាតាបិតា។ ការតបស្នងសងគុណដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សរសើរជាងគេ ហើយដែលបានអានិសង្ស បានបុណ្យជាងគេគឺ បើមាតាបិតាយើងមិនទាន់មានសទ្ធា ទាក់ទាញគាត់ឱ្យមានសទ្ធា បើមិនទាន់មានសីល ពន្យល់ទាក់ទាញគាត់ឱ្យមានសីល បើមិនទាន់មានធម៌ស្ងប់ក្នុងភាវនា គួររកទីកន្លែងស្ងប់ឱ្យគាត់ នៅចំរើនភាវនា កុំឱ្យមកជំពាក់ជំពិនជាមួយកូនជាមួយចៅ ដែលជាបុព្វហេតុធ្វើឱ្យគាត់មិនមានអារម្មណ៍ស្ងប់ ក្នុងការឈានទៅរកសុគតិភពនាលោកខាងនាយ។ កូនចៅគួរតែផ្គត់ផ្គង់សំលៀងបំពាក់ ម្ហូបអាហារ ទីស្នាក់ទីអាស្រ័យ និងថ្នាំរក្សាព្យាបាល ដល់គាត់ឱ្យបានគ្រប់គ្រាន់ ដោយមួយភាគគាត់ទុកប្រើប្រាស់ខ្លួនឯងនិងមួយ ភាគទៀតយកធ្វើបុណ្យតាមសទ្ធាជ្រះថ្លារបស់គាត់ ។

## **ធ្វើគុណពេលណាទើបបានបុណ្យច្រើន?**

When do we pay gratitude that gain us much merits

ការធ្វើគុណឬធ្វើបុណ្យ យើងធ្វើពេលណាបានបុណ្យពេលនោះ តែចំពោះមាតាបិតាយើងគួរធ្វើនិងបំពេញនៅពេលដែលលោកទាំងទ្វេរនៅមានជីវិតនៅឡើយ។ ការធ្វើបុណ្យនៅពេលដែលមាតាបិតាយើងនៅមានជីវិតនៅឡើយ ខ្មែរយើងហៅថា*ធ្វើបុណ្យខែភ្លឺ* តែពេលលោកទាំងពីរស្លាប់ទៅទើបយើងខំធ្វើបុណ្យ ខ្មែរយើងហៅថា*ធ្វើបុណ្យខែងងឹត*។ ធម្មតាខែភ្លឺគឺភ្នែករបស់យើងមើលឃើញច្បាស់ថា គាត់នៅមានកំឡាំង នៅមានធ្មេញទំពារបាន នៅមានភ្នែកភ្លឺ ហើយដឹងថាគាត់មានចំណង់ចំណូលចិត្តយ៉ាងណាចូលចិត្តរស់ជាតិម្ហូបបែបណា។ យើងនឹងសប្បាយរីករាយនៅពេលដែលឃើញគាត់ដើរបាន និយាយបានស្តាប់បាន មើលឃើញ ទំពារបានជាដើម ជាពិសេសគាត់អាចចាំធម៌ បដិបត្តិធម៌ និងជំរះចិត្តរបស់គាត់បានផូរផង់តាមរយះជំនួយពីខាងក្រៅរបស់យើងដែលជាកូនចៅទាំងឡាយ។ ការធ្វើបុណ្យខែភ្លឺនេះបានបុណ្យទាំងសងខាង យើងដែលជាអ្នកធ្វើក៏បានបុណ្យ មាតាបិតាយើងក៏បានបុណ្យ។ តែបើយើងធ្វើបុណ្យខែងងឹតវិញ អ្វីៗទាំងអស់យើងមើលមិនឃើញសោះ។ ការធ្វើបុណ្យខែងងឹតនេះវាបានបុណ្យដែរ តែបាន

ចំពោះយើងដែលជាអ្នកធ្វើ ប៉ុន្តែមាតាបិតារបស់យើងមិនដឹងជាគាត់បានទទួលឬមួយយ៉ាងណា? ដូចជាយើងធ្វើរសំបុត្រដោយមិនបានស្គាល់អាស័យដ្ឋានច្បាស់លាស់ដូច្នោះឯង ។

តាមរយៈការធ្វើបុណ្យខែភ្លឺ និងធ្វើបុណ្យខែងងឹតនេះ បណ្ឌិតអ៊ូ ចុង បានបញ្ជាក់ថា :

ត្រូវធ្វើបុណ្យខ្មើត ម៉ែឪហូបកើត កំពុងស្រេកឃ្លាន
ម៉ែឪនៅរស់ កូនត្រូវធ្វើទាន បំបាត់ក្ដីឃ្លាន
ហៅធ្វើបុណ្យខ្មើត ។
ហៅបុណ្យខែភ្លឺ កុំចាំគាត់ឈឺ បរិភោគលែងកើត
ជូនគាត់កាលជា ហៅថាបុណ្យខ្មើត គាត់បរិភោគកើត
បានជាងរនោច ។
លុះបាត់ជីវិត បុណ្យខែងងឹត ដូចថ្ងៃ១០រោច
កូចចៅទាំងឡាយ យកបាយឱ្យខ្មោច ម៉ែឥតប្រយោជន៍
ខ្មោចណាចេះស៊ី ។

ដូច្នេះ កូនចៅទាំងឡាយគួរតែខំបំរើប្រណិបត្តិចំពោះមាតាបិតា ទាន់ពេលគាត់នៅរស់ ទើបយើងមិនមានវិប្បដិសារីនៅពេលដែលគាត់ធ្វើមរណកាលបាត់ទៅ ។

## គុណរបស់មាតាបិតា តាមទស្សនៈរបស់ខ្មែរយើង

The virtue of parents follows Khmer perspectives.

តាមពិតទៅ ខ្មែរយើងហាក់បីដូចជាមានជំនឿថា ការដឹងគុណចំពោះមាតាបិតាជាឥទ្ធិពលមួយរបស់ព្រះពុទ្ធសាសនា ។ តែតាមការពិតទៅ ខ្មែរយើងចេះដឹងគុណចំពោះមាតាបិតានិងអ្នកមានគុណទាំងឡាយតាំងពីរបុរាណកាលមកម្លេះ ។ ដែលពេលនោះបុព្វជនខ្មែរយើងពុំទាន់បានទទួលឥទ្ធិពលសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនានៅឡើយទេ ។ តែខ្មែរយើងត្រូវបានគេស្រាវជ្រាវឃើញថាជាសង្គមមួយដែលមានលក្ខណៈជាសង្គមមាតាធិបតេយ្យ(matriarch) (ការយកមាតាជាធំ) និងជាសង្គមបិតាធិបតេយ្យ (patriarch) (ការយកបីតាជាធំ)ផងដែរ ។ យើងអាចសង្កេតឃើញភស្តុតាងបានខ្លះតាមរយៈការបដិបត្តិសាសនាអ្នកតារបស់ខ្មែរយើង ។ អ្នកតា មកពីពាក្យថាអ្នក ដែលប្រើជាពាក្យគោរព និង តា ដែលជាពាក្យចុងក្រោយរបស់ពាក្យខ្មែរយើងពីរម៉ាត់គឺមាតានិងបិតា ។ ដូច្នេះមាតាបិតាជាព្រះខ្ពស់បំផុតដែលខ្មែរយើងគោរពនិងដឹងគុណ ។ ការគោរពនេះ យូរទៅៗក្លាយទៅជាអ្នកម្ចាស់ទឹកម្ចាស់ដី ដែលប្រជាជនខ្មែរយើងជំនាន់ក្រោយគិតថាជាដួងព្រលឹងរបស់ម្ចាស់ស្រុក ម្ចាស់ទឹក ម្ចាស់ដី

តាមធ្វើ តាមកាច់កូនចៅទៅវិញ ។ យើងអាចសង្កេតឃើញថា គំនិតនេះអាចជាឥទ្ធិពលរបស់សាសនាបរទេសគឺ ព្រាហ្មណ៍សាសនានេះឯង ដែលគេមិនចង់ឱ្យខ្មែរយើងគោរពរាប់អានព្រះច្រើនអង្គ ក្រៅអំពីឱ្យគោរពរាប់អានតែព្រះរបស់គេគឺព្រះព្រហ្ម ព្រះសិវៈ និងព្រះវិស្ណុតែប៉ុណ្ណោះ ។

ចំណែកព្រះមហាក្សត្រខ្មែរយើងគ្រប់ព្រះអង្គ រាប់តាំងពីបុរាណកាលតរៀងមក តែងមានព្រះរាជប្រពៃណីគោរពចំពោះមាតាបិតាជានិច្ច ។ ជាក់ស្តែងភស្តុតាងខាងស្ថាបត្យកម្មដែលមានពាសពេញផ្ទៃប្រទេសកម្ពុជាយើងនិងបណ្តាប្រទេសជិតខាង ។ ទាំងតួប្រាង្គប្រាសាទនិងសិលាចារឹកទាំងអស់នោះ ក្រៅអំពីគោលបំណងដើម្បីឧទ្ទិសចំពោះព្រះអាទិទេព្យនិងខ្លួនព្រះអង្គផ្ទាល់ រមែងឃើញចេញលក្ខណៈសំគាល់និងសិលាចារឹកដែលសំដែងចេញនូវការដឹងគុណនិងការតបស្នងសងគុណចំពោះមាតាបិតា និងវង្សត្រកូលរបស់ព្រះអង្គ ។

ការគោរពមាតាបិតាដោយប្រៀបព្រះមេទាំងពីរទៅនឹងព្រះអាទិទេព្យ ព្រះជាម្ចាស់ឬព្រះខ្ពស់ជាងព្រះអ្វីៗទាំងអស់របស់ខ្មែរយើង មិនបានរាំងស្ទះដោយឥទ្ធិពលរបស់ព្រះពុទ្ធសាសនាឡើយ ។ ព្រះសង្ឃខ្មែរយើងតែងទេសនាប្រៀនប្រដៅពុទ្ធបរិស័ទកុំឱ្យភ្លេចបូជាព្រះកន្លោង ។ បើយកចង្ហាន់ទៅថ្វាយព្រះសង្ឃនៅឯវត្ត ចូរកុំភ្លេចយកទៅថ្វាយព្រះកន្លោងជាមុនសិន បើថ្វាយបង្គំព្រះសង្ឃនៅឯវត្ត ចូរកុំភ្លេចថ្វាយបង្គំព្រះកន្លោង ជាមុនសិន ជាដើម ។ ភស្តុតាងដែលយើងឃើញច្បាស់ជាងគេ គឺកំណាព្យបទកាកគតិរបស់បណ្ឌិត *អ៊ូ ចុង* ក្នុងចំណងជើងថា “ *ច្បាប់គោរពមាតាបិតា*” ក្នុងវគ្គខ្លះដូចជា :

ម្យ៉ាងទៀតធ្វើបុណ្យ    ច្រើនតែចោលគុណ    គ្មានគិតរិះរេ
បោលទៅតែវត្ត    ម្តាយអត់ទទេ    ព្រោះជឿតាមគេ
    រកបុណ្យខាងក្រៅ ។
ដើមបុណ្យលើផ្ទះ    ខ្លួនកើតទាន់ព្រះ    កន្លោងគង់នៅ
បានត្រីត្រកាល    ទុកក្បាលឱ្យឪ    កណ្តាលនាំទៅ
    យកបុណ្យឯវត្ត ។
នេះហៅបុណ្យខុស    ទាំងស្រីទាំងប្រុស    ខ្ញុំប្រាប់កុំខឹង
ម៉ែឪនៅរស់    ចូរអស់លោកប្រឹង    ធ្វេញគាត់នៅរឹង
    បានឆ្ងាញ់ពិសា ។
ខ្លះជឿបុណ្យខ្លាំង    ឃូរម្ហូបទាំងឆ្នាំង    យកទៅវត្តវ៉ា
ម៉ែឪអត់ឃ្លាន    ចង់បានណាស់ណា    ភ្លយសួរកូនថា

មានសល់ឬទេ? ។

ព្រឹកឡើងឃ្លានបាយ ញ៉ូរពោះញើសខ្វាយ ឃើញសម្លគេ
កូនឆ្លើយរឹងថ្កាន មិនបានសល់ទេ ខ្ញុំស្លូ គ្រាន់តែ
ទៅវត្តទេ ឪ ។

ឪពុកសួរថា បើជួសកាលណា ចែកឪខ្លះទៅ
កូនខ្លះឆ្លើយប្រាប់ ថាបាបណាស់ឪ គេថាមិនត្រូវ
ឪស៊ីមុនលោក ។

ម៉ែឪចាស់ៗ ព្រឹកឡើងឃ្លានណាស់ គួរឱ្យវិយោគ
ឪទារពិសា កូនថាមុនលោក ពុំបានបរិភោគ
គេឱ្យបាបផង ។

នេះបុណ្យផ្កាប់មុខ ឬបុណ្យចោលស្រុក ព្រោះដើរផ្លូវឆ្គង
បុណ្យមិនត្រកាល វិសាលឡើយហោង ព្រោះដើរកន្លង
ឱ្យម៉ែឪអត់ ។

ពួកជនឈ្លានពាន មិនចេះធ្វើទាន ច្រើនធ្វើទានក្បត់
សទ្ធាមិនជ្រៅ ជ្រុលទៅតែវត្ត ឱ្យព្រះដើមអត់
ស្រែកឃ្លានពេកក្រៃ ។

បណ្ឌិតអ៊្វ ចុង លោកបានបញ្ជាក់ច្បាស់អំពីព្រះកន្លោងនៅក្នុងផ្ទះ និងវិបត្តិនៃការមិនស្គាល់ព្រះពិតប្រាកដថា :

ព្រះពុទ្ធដាក់ឈ្មោះ
បាលីពីរោះ បុព្វទេវា “ ទេវតាខាងដើម”
អ្នកផ្ដើមរក្សា បុត្រីបុត្រា ហៅទេវតាផ្ទះ ។
គឺម្ដាយឪពុក
ជាអ្នកម្ចាស់ស្រុក កូនមិនសំពះ ម៉ែឪទូន្មាន
ឈ្លានពានចង់ឈ្នះ សត្រូវនឹងព្រះ កន្លោងអាត្មា ។
ប្រទូសរ៉ាយ
នឹងឪពុកម្ដាយ ស្រែកហៅទេវតា អំពីខាងក្រៅ

| | | | |
|---|---|---|---|
| ដឹងនៅឯណា | ឈ្មោះនឹងទេវតា | គឺម៉ែឪឯង | ។ |
| | តែងតែលំបាក | | |
| ក្រីក្រតោកយ៉ាក | ជាតិនេះឃើញស្តែង | ហើយទៅវេងទុក្ខ | |
| ខាងមុខពុំលែង | លុះភ័យទើបស្វែង | រកហោរគ្រូទាយ | ។ |



## ឯកសារយោង


១. សុត្តន្តបិដក, ទីឃនិកាយ, បាដិកវគ្គ

២. បណ្ឌិតអ៊ូ ចុង, ច្បាប់គោរពមាតាបិតា, ព្រឹត្តិប័ត្រស្រាវជ្រាវ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ចាប់ពីច្បាប់ទី១១ លេខ១១០ កុម្ភៈ ២០០៤ ដល់ច្បាប់ទី១១ លេខ១១៧ កញ្ញា ២០០៤

៣. ឈុន គឹមអៀត, ទ្រឹស្តីកម្មផល, ព.ស.២៥៤៥, គ.ស.២០០១

៤. ព្រះភិក្ខុវោទានោ សេង សុភ័ណ, ធម្មនុញ្ញជីវិត(ប្រែជាភាសាខ្មែរ), សកលវិទ្យាល័យមហាចុឡាលុងកន, ព.ស.២៥៤៦ គ.ស.២០០២

៥. Dhamma Pitaka, Dictionary of Buddhism, Bangkok, B.E.2538